ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

និយ័តករទូរគមនាគមន៍កម្ពុជា

លេខ :....២៤៣៩......ន.ទ.ក.

# សេចក្ដីណែនាំ

## ស្ដីពី

## ការគ្រប់គ្រង និងបង្ការអគ្គិភ័យបណ្ដាលមកពីចរន្តអគ្គិសនី

ដើម្បីចូលរួមក្នុងការកាត់បន្ថយចំណាយលើការប្រើប្រាស់ថាមពលអគ្គិសនី និងដើម្បីបង្ការនិងទប់ស្កាត់អគ្គិភ័យដែលអាចកើតឡើងជាយថាហេតុ ខ្ញុំសូមធ្វើការណែនាំដល់ឯកឧត្តម លោក លោកស្រី ជាថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិកទាំងអស់ដូចខាងក្រោម÷

១. ផ្ដាច់ចរន្តអគ្គិសនី (បិទអំពូលភ្លើង ម៉ាស៊ីនត្រជាក់ និងបរិក្ខារអេឡិចត្រូនិច) ទាំងអស់នៅពេលផុតម៉ោងរដ្ឋបាល ឬឈប់សម្រាកពីការងារ លើកលែងតែបន្ទប់ដែលចាំបាច់បំផុត **(Server Room , Camera Room)**។

២. ផ្ដាច់ចរន្តអគ្គិសនីទាំងអស់ក្នុងបរិវេណអគារ ឬបន្ទប់ដែលស្ថិតក្នុងសមត្ថកិច្ចទទួលខុសត្រូវរបស់នាយកដ្ឋាន និងអង្គភាពនីមួយៗនៅថ្ងៃឈប់សំរាក (ថ្ងៃសៅរ៍ ថ្ងៃអាទិត្យ និងថ្ងៃបុណ្យជាតិ) លើកលែងបន្ទប់ដែលចាំបាច់បំផុត **(Server Room, Camera Room)**។

ទទួលបានសេចក្ដីណែនាំនេះ ឯកឧត្ដម លោក លោកស្រី ជាថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិកទាំងអស់ក្រោមឱវាទ ន.ទ.ក ត្រូវចូលរួមអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់បំផុត។

ថ្ងៃ អង្គារ ៨រោច ខែ មិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ២០២០

**ប្រធាន**

**ថោង ចិន្តា**

**ចម្លងជូន÷**

- ឯកឧត្តមសមាជិក
- គ្រប់នាយកដ្ឋាន និងអង្គភាព
  "**ដើម្បីផ្សព្វផ្សាយអនុវត្ត**"
- ឯកសារ-កាលប្បវត្តិ

វិថីលេខ ១០២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ
(855) 23 72 23 33
(855) 23 72 32 22
info@trc.gov.kh
www.trc.gov.kh